**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ១០៤/០០៤/២០០៦
ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

**សេចក្ដីសម្រេច**
លេខ : ០៧៦/០០៣/២០០៦ កបធ.ច
ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសេចក្ដីសម្រេចលេខ ០៦៩/០០១/២០០៥ កបធ.ច ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៣៦៧ រស ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ របស់សម្ដេច **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ១៥ ថ្មី និងប្រការ ៤៨ ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ វេលាម៉ោង ១០ ព្រឹក ។

**ក្រោយពីបានស្ដាប់សេចក្ដីរាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ត្រង់កថាខណ្ឌទី២ ឃ្លាទី ១ ចែងថា *" បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ។"* និងមាត្រា ១៦ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបានចែងថា *" ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង វិសោធនកម្មនៃច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាបានអនុម័តត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យមើលច្បាប់ទាំងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ "* ។ សំណើរបស់ សម្ដេច **ហេង សំរិន** ប្រធានរដ្ឋសភា លេខ ៣៦៧ រស ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ គឺស្របតាមរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន ។

- យល់ឃើញថា វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ត្រង់ប្រការ ១៥ ថ្មី និងប្រការ ៤៨ ថ្មី ពុំមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

## **សម្រេច**

**មាត្រា១**~ វិសោធនកម្មប្រការ ១៥ ថ្មី និងប្រការ ៤៨ ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា,ដែលបានអនុម័តនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា២**~ សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន